# វិទ្យាស្ថានគរុកោសល្យបាត់ដំបង

BATTAMBANG TEACHER EDUCATION COLLEGE

**ប្រធានបទ៖**

# ការប្រើប្រាស់គោលវិធីលំនាំបង្រៀនសកម្មភាព ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ ដើម្បីជួយសិស្សក្នុងការអានស្ទាត់លើមុខវិជ្ជាភាសាខ្មែរ

របាយការណ៍ស្រាវជ្រាវអប់រំ

សម្រាប់បំពេញលក្ខខណ្ឌបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រអប់រំគ្រូបង្រៀន

ឯកទេស បឋមសិក្សា

**ឈ្មោះ៖ សុវណ្ណា មករា**

**កញ្ញា ២០២២**

# វិទ្យាស្ថានគរុកោសល្យបាត់ដំបង

BATTAMBANG TEACHER EDUCATION COLLEGE

**ប្រធានបទៈ**

## ការប្រើប្រាស់គោលវិធីលំនាំបង្រៀនសកម្មភាព ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ ដើម្បីជួយសិស្សក្នុងការអានស្ទាត់លើមុខវិជ្ជាភាសាខ្មែរ

របាយការណ៍ស្រាវជ្រាវអប់រំ

សម្រាប់បំពេញលក្ខខណ្ឌបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រអប់រំគ្រូបង្រៀន

ឯកទេស បឋមសិក្សា

**ឈ្មោះ  សុវណ្ណា មករា**

**គណៈកម្មការវាយតម្លៃៈ លោក សាង ធិតា** ហត្ថលេខា......................

**លោកស្រី សេង ហឿង** ហត្ថលេខា.....................

**កញ្ញា ២០២២**

# មូលន័យសង្ខេប

ការលើកកម្ពស់ផ្នែកអំណានសម្រាប់កុមារកម្ពុជាជាកត្តាលីករមួយជួយជំរុញដល់ប្រព័ន្ធអប់រំមានភាពប្រសើរឡើងជាងមុន។ ដោយមើលឃើញពីអត្ថប្រយោជន៍នៃការអាន ក្នុងអំឡុងកម្មសិក្សាគរុកោសល្យបានសង្កេតឃើញបញ្ហាមួយសិស្សថ្នាក់ទី៣ លទ្ធភាពក្នុងការអានមានកម្រិតទាប វាជាផលលំបាកមួយ ព្រោះពួកគេមិនអាចឈានដល់ការយល់ន័យនៃអត្ថបទដែលបានអានរួច។ ប្រធានបទស្រាវជ្រាវមួយនេះបង្កើតក្នុងគោលបំណងដើម្បីធ្វើការប្រៀបធៀបការអានស្ទាត់របស់សិស្សក្រោយពេលពួកគេទទួលបានការអនុវត្តគោលវិធីលំនាំបង្រៀនសកម្មភាព **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** ជាមួយនិងគោលវិធីលំនាំបង្រៀនសកម្មភាព**ត្រាប់តាម**។

ការសិក្សាស្រាវជ្រាវនេះតាមបែប**បរិមាណវិស័យ**ធ្វើការពិសោធទៅលើសិស្សពីរក្រុមនៅកម្រិតថ្នាក់ទី៣ នៃសាលាបឋមសិក្សា**ពោធិវង្ស** ខេត្តបាត់ដំបង។ សំណាកដែលចូលរួមសរុប ៥២ នាក់ស្រី១៨នាក់។ ការស្រាវជ្រាវនេះមានការដាក់តេស្តដើមកាល និងតេស្តចុងកាល ព្រមទាំងបង្កើតកម្រងសំណួរកម្រិតពេញចិត្តលើសកម្មភាពបង្រៀន **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** ដើម្បីប្រមូលទិន្នន័យ។ លទ្ធផលក្នុងធ្វើតេស្តអានស្ទាត់បានបង្ហាញថា ក្រុម **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** មានពិន្ទុខ្ពស់ជាងក្រុម **ត្រាប់តាម**។ ពោលគឺប្រសិទ្ធភាពការអានស្ទាត់របស់ក្រុម **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ**ទទួលបាន៦៦% រីឯក្រុម **ត្រាប់តាម** ទទួលបាន៥០%។ លទ្ធផលកម្រងសំណួរស្ទង់មតិលើក្រុមពិសោធន៍ទទួលបាន ៩១.៨%។

តាមរយៈលទ្ធផលខាងលើយើងអាចសន្និដ្ឋានបានថា លោកគ្រូអ្នកគ្រូ គរុសិស្ស-និស្សិត ឪពុកម្តាយ អាណាព្យាបាលសិស្សអាចយកគោលវិធីលំនាំបង្រៀនសកម្មភាព **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** ទៅអនុវត្តន៍បានក្នុងការជួយជម្រុញឱ្យកុមារមានលទ្ធភាពអានបានស្ទាត់ជំនាញ។ ប្រសិនបើបញ្ហាត្រូវបានដោះស្រាយទៅលើការអានស្ទាត់របស់សិស្សរួចរាល់តាំងពីកម្រិតបឋមសិក្សា នៅពេលកុមារឆ្លងភូមិសិក្សាពួកគេអាចទទួលបានចំណេះដឹងពេញលេញបន្ថែមទៀត។

# លិខិតដឹកនាំការស្រាវជ្រាវរបស់គ្រូឧទ្ទេសដឹកនាំ

កម្មវិធីថ្នាក់បរិញ្ញាបត្រអប់រំ បឋមសិក្សា១២+៤

ឈ្មោះបេក្ខជន៖ **សុវណ្ណ មករា**

ចំណងជើងនិក្ខេបបទ/របាយការណ៍ស្រាវជ្រាវអប់រំ៖**ការប្រើប្រាស់គោលវិធីលំនាំបង្រៀសកម្មភាព ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ ដើម្បីជួយសិស្សក្នុងការអានស្ទាត់លើមុខវិជ្ជាភាសាខ្មែរ**

សូមបញ្ជាក់ថា ការស្រាវជ្រាវដែលជានិក្ខេបបទ/របាយការណ៍ស្រាវជ្រាវសម្រាប់បំពេញលក្ខខណ្ឌយកសញ្ញាបត្របរិញ្ញាបត្រអប់រំដែលមានចំណងជើងដូចខាងលើនេះ ត្រូវបានធ្វើដោយបេក្ខជនដែលមានឈ្មោះខាងលើ ក្រោមការដឹកនាំរបស់ខ្ញុំផ្ទាល់។ ខ្លឹមសារនិក្ខេបបទនេះពុំទាន់មាននៅក្នុងសរសេរយកសញ្ញាបត្រកម្រិតណាមួយឡើយ។ ក្នុងការរៀបចំនិក្ខេបបទនេះ៖

.................................................................................................................................

.................................................................................................................................

.................................................................................................................................

.................................................................................................................................

.................................................................................................................................

.................................................................................................................................

.................................................................................................................................

.................................................................................................................................

.................................................................................................................................

ហត្ថលេខាគ្រូឧទ្ទេសដឹកនាំ៖

កាលបរិច្ឆេទ៖ ..........................................................................................

# លិខិតដឹកនាំការស្រាវជ្រាវរបស់បេក្ខជន

ខ្ញុំបាទឈ្មោះ **សុវណ្ណ មករា** សូមបញ្ជាក់ថារបាយការណ៍ស្រាវជ្រាវដែលមានចំណងជើងថា ៖ **ការប្រើប្រាស់គោលវិធីលំនាំបង្រៀនសកម្មភាព ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ ដើម្បីជួយសិស្សក្នុងការអានស្ទាត់លើមុខវិជ្ជាភាសាខ្មែរ** សម្រាប់បំពេញលក្ខខណ្ឌយកសញ្ញាបត្រថ្នាក់បរិញ្ញាបត្រអប់រំគ្រូបង្រៀននៅវិទ្យាស្ថានគរុកោសល្យបាត់ដំបង គឺជាស្នាដៃរបស់នាងខ្ញុំ/ខ្ញុំបាទទាំងស្រុង។ស្នាដៃនេះពុំទាន់ត្រូវបានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់យកសញ្ញាបត្រនៅសាកលវិទ្យាល័យណាមួយ ឬក៏វិទ្យាស្ថានថ្នាក់ស្មើណាមួយឡើយ។ ពុំមានសេចក្តីដកស្រង់ឬខ្លឹមសារណាមួយដែលត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។

ហត្ថលេខាបេក្ខជន៖ ...................................................................

កាលបរិច្ឆេទ៖...........................................................................

ហត្ថលេខាគ្រូឧទ្ទេសដឹកនាំ៖.....................................................

កាលបរិច្ឆេទ៖...........................................................................

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ**សុវណ្ណ មករា** ជាគរុសិស្ស១២+៤(បឋមសិក្សា)ជំនាន់ទី១ឆ្នាំទី៤នៃវិទ្យាស្ថានគរុកោសល្យបាត់ដំបង សូមថ្លែងនូវសេចក្តីដឹងគុណដ៏ជ្រាលជ្រៅដែលពុំអាចកាត់ថ្លៃបានចំពោះលោកឪពុក **តេខ សុវណ្ណ** និងអ្នកម្តាយ **ហៀង សាង** ដែលបានផ្តល់កំណើត ព្រមទាំងបងប្រុសបងស្រីសម្រាប់ការជួយបីបាច់ថែរក្សានិងទំនុកបំរុងយ៉ាងពេញទំហឹងក្នុងការរស់នៅ និងការសិក្សារៀនសូត្រក្រេបយកចំណេះដឹងដែលធ្វើអោយកូនៗទទួលបានផ្លែផ្កា មានអនាគតល្អប្រសើរដូចសព្វថ្ងៃនេះ ដើម្បីជាទុនក្នុងការចូលរួមបណ្តុះបណ្តាលធនធានមនុស្សដែលជាប្រភពយ៉ាងសំខាន់បំផុតក្នុងការកសាងប្រទេសជាតិឲ្យមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ លោកគ្រូឧទ្ទេសដឹកនាំ **ហ៊ាង សុផុន** ដែលបានខិតខំចំណាយពេលវេលាដ៏មានតម្លៃបង្ហាត់បង្រៀននិងដឹកនាំត្រួតពិនិត្យ កែតម្រូវដល់ខ្ញុំព្រមទាំងបញ្ចេញគំនិតសម្រាប់ការច្នៃប្រឌិតបន្ថែមទៀតក្នុងកិច្ចការស្រាវជ្រាវនេះតាំងពីដំណើរការចាប់ផ្តើមរហូតដល់របាយការណ៍ចងក្រងប្រកបដោយជោគជ័យ។

សូមថ្លែងអំណរគុណចំពោះលោកស្រី **នង ឈានី** ជានាយិកា អ្នកគ្រូ **ប៉ែន សុតា** ជាគ្រូបន្ទុកថ្នាក់ទី៣ ក និងអ្នកគ្រូ **ប៉ែន ឥណ្ណារ៉ា** ជាគ្រូបន្ទុកថ្នាក់ទី៣ ខ ព្រមទាំងប្អូនៗទាំងពីរថ្នាក់នៃសាលាបឋមសិក្សាពោធិវង្ស ដែលបានអនុញ្ញាតឱ្យខ្ញុំបាទបានចុះស្រាវជ្រាវពិសោធន៍។ សូមអរគុណយ៉ាងក្រៃលែងចំពោះអ្នកគ្រូបន្ទុកថ្នាក់ និងប្អូនៗសិស្សានុសិស្សដែលចូលរួមយ៉ាងសកម្មភាពចំពោះការស្រាវជ្រាវមួយនេះផងដែរ។

ជាពិសេសសូមថ្លែងអំណរគុណដល់លោកឯកត្តមនាយក **ចិន ឆុំ** នាយករង គណៈគ្រប់គ្រងសាលា ក៏ដូចជាលោកគ្រូអ្នកគ្រូ សាស្ត្រាចារ្យឧទ្ទេសទាំងអស់នៃវិទ្យាស្ថានគរុកោសល្យបាត់ដំបងដែលបានខិតខំព្យាយាមបង្រៀន ក៏ដូចជាបណ្តុះបណ្តាលយើងខ្ញុំទាំងអស់គ្នា ទាំងចំណេះដឹងទូទៅទាំងវិធីសាស្ត្របង្រៀនទៅលើឯកទេសនីមួយៗដែលជាទុនដ៏ថ្លៃថ្លាសម្រាប់យើងខ្ញុំយកទៅប្រើ

ប្រាស់ប្រកបដោយជំនាញ និងវិជ្ជា ជីវៈច្បាស់លាស់ ។ ជាចុងបញ្ចប់នៃសេចក្តីថ្លែងអំណរគុណនេះ យើងខ្ញុំទាំងអស់គ្នាសូមប្រសិទ្ធពរជ័យសិរីសួស្តីមហាបវរប្រសើរចូរមានដល់ លោកអ្នកមានគុណទាំងពីរ លោកនាយក នាយករង គណៈគ្រប់គ្រងសាលា ក៏ដូចជាលោកគ្រូអ្នកគ្រូ សាស្ត្រាចារ្យ ឧទ្ទេសឲ្យជួបប្រទះតែសេចក្តីសុខសុភមង្គល និងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លាងឃ្លាតឡើយ ។

# បញ្ជីតារាងបម្រាប្រ

តារាង១ ការប្រៀបធៀបបលទ្ធផលតេស្តមុនពេលនិងក្រោយពេលរៀនរបស់ក្រុមត្រាប់តាម....................១៣

តារាង២ ការប្រៀបធៀបបលទ្ធផលតេស្តមុនពេលនិងក្រោយពេលរៀនរបស់ក្រុមខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ.....១៤

តារាង៣ ការប្រៀបធៀបបលទ្ធផលតេស្តចុងកាលរវាងក្រុមត្រាប់តាម និង ក្រុម ខ្ញុំធ្វើ យើងធ្វើអ្នកធ្វើ........១៤

តារាង៤ លទ្ធផលកម្រងសំណួរស្ទង់មតិទៅលើសិស្សដែលទទួលបានការអនុវត្តលំនាំបង្រៀនសកម្មភាព ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ....................................................................................................................................១៦

ក្រាហ្វទី១៖ លទ្ធផលការប្រៀបធៀបនៃមធ្យមភាគតេស្តមុនពេលនិងក្រោយពេលបង្រៀនរបស់ក្រុម ត្រាប់តាម និង ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ..........................................................................................១៥

# មាតិកា

**មូលន័យសង្ខេប** ........ I

**លិខិតដឹកនាំការស្រាវជ្រាវរបស់គ្រូឧទ្ទេសដឹកនាំ** ........ I I

**លិខិតដឹកនាំការស្រាវជ្រាវរបស់បេក្ខជន** ........ I I I

**សេចក្តីថ្លែងអំណរគុណ** ........ I V

**បញ្ជីតារាងឬក្រាហ្វ** ........ VI

## ជំពូកទី១

## សេចក្តីផ្តើម

១.១. សារតានៃការស្រាវជ្រាវ ........ ១

១.២. បញ្ហានៃការស្រាវជ្រាវ ........ ២

១.៤. សំណួរនៃការស្រាវជ្រាវ ........ ៣

១.៥. សម្មតិកម្ម ........ ៣

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣

១.៧. ដែនកំណត់នៃការស្រាវជ្រាវ ........ ៤

១.៨. ការពន្យល់បញ្ញត្តិសំខាន់ៗ ........ ៤

## ជំពូកទី២

## វិចារណនិពន្ធន៍

២.១. និយមន័យពាក្យគន្លឹះ ........ ៥

*២.១.១. ខ្ញុំធ្វើ យើងធ្វើ និងអ្នកធ្វើ ........ ៥*

*២.១.២. ការចេះអានស្ទាត់ ........ ៥*

២.២. លក្ខណៈទូទៅនៃការបង្រៀនអំណាន ........ ៥

២.៣. ការអនុវត្តគោលវិធីលំនាំបង្រៀនសកម្មភាព ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ ........ ៦

២.៤. លទ្ធផលតេស្តវង្វាយតម្លៃ PISA2018 ........ ៦

២.៥. ការវាស់វែងការអានស្ទាត់របស់សិស្ស ........ ៧

## ជំពូកទី៣

## វិធីសាស្ត្រនៃការស្រាវជ្រាវ

៣.១. វិធីសាស្ត្រ..........១០
៣.២. តំណាងគំរូនិងវិធីនៃការជ្រើសរើស..........១០
៣.៣. ទីតាំងនៃការស្រាវជ្រាវ..........១១
៣.៤. ឧបករណ៍នៃការស្រាវជ្រាវ..........១១
៣.៥. វិធីសាស្ត្រប្រមូលទិន្នន័យ..........១១
៣.៦. ការវិភាគទិន្នន័យ..........១១
៣.៧. ក្រមសីលធម៌ស្រាវជ្រាវ..........១២

## ជំពូក៤

## លទ្ធផលនៃការស្រាវជ្រាវ

៤.១.លទ្ធផលនៃការដាក់តេស្ត..........១៣
៤.២. លទ្ធផលនៃការកម្រងសំណួរស្ទង់មតិ..........15
៤.២.ការពិភាក្សា..........១៦

## ជំពូកទី៥

## សេចក្តីសន្និដ្ឋាននិងអនុសាសន៍

៥.១.សេចក្តីសន្និដ្ឋាន..........១៩
៥.២.ចំណុចខ្វះខាតនៃការស្រាវជ្រាវ..........១៩
៥.៣.អនុសាសន៍..........២០
៥.៤.ដែនកំណត់និងទិសដៅនាពេលអនាគតនៃការស្រាវជ្រាវ..........២០

## ឯកសារយោង

## ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ កម្រងតេស្ត(តេស្តដើមកាលនិងតេស្តចុងកាល)
ឧបសម្ព័ន្ធទី២៖ កម្រងសំណួរស្ទង់មតិលើក្រុម ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ
ឧបសម្ព័ន្ធទី៣៖ ផែនការបង្រៀនរបស់ក្រុម ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ
ឧបសម្ព័ន្ធទី៤៖ ផែនការបង្រៀនរបស់ក្រុម ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ
ឧបសម្ព័ន្ធទី៥៖ កម្រងរូបភាព

# ជំពូកទី១

# សេចក្តីផ្តើម

## ១.១. សាវតានៃការស្រាវជ្រាវ

ការអានគឺជាផ្នែកមួយដ៏សំខាន់សម្រាប់ការសិក្សារៀនសូត្ររបស់កុមារនិងមនុស្សទូទៅក្នុងប្រទេស។ ការលើកកម្ពស់ផ្នែកអំណានសម្រាប់កុមារកម្ពុជាជាកត្តាលីករមួយជួយជំរុញដល់ប្រព័ន្ធអប់រំមានភាពប្រសើរឡើងជាងមុន។ នៅថ្ងៃទី **១១** ខែ **មីនា** ឆ្នាំ**២០១៦** ទិវាជាតិអំណានត្រូវបានបង្កើតឡើងជាលើកដំបូងក្នុងប្រទេសកម្ពុជាបន្ទាប់ពីរាជរដ្ឋាភិបាលបានចេញអនុក្រឹត្យស្តីពីទិវាជាតិអំណានដើម្បីប្រារព្ធពិធីនេះជារៀងរាល់ឆ្នាំ (ភ្នំពេញ ប៉ាតង់លេខ. ១២០អនក្រ.បក, ២០១៥)។

លោកបណ្ឌិតសភាចារ្យ **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា បានមានប្រសាសន៍ថា ទិវាជាតិអំណាននេះប្រារព្ធឡើងដើម្បីលើកកម្ពស់វប្បធម៌អាននិងជំរុញយុវជនអានសៀវភៅឱ្យបានច្រើន។ អំណានពិតជាមានសារៈសំខាន់ណាស់ក្នុងការរួមចំណែកកាត់បន្ថយអនក្ខរភាពនិងទទួលយកចំណេះដឹងពីគ្រប់ទិសទីដើម្បីបើកគំនិតឱ្យបានទូលំទូលាយ (ហង់ ជួនណារ៉ុន, ២០១៦)។ យោងតាមរបាយការណ៍របស់ **World Bank** កាលឆ្នាំ២០១៤ បង្ហាញថា ជាទូទៅពិន្ទុអំណាននៅមានកម្រិតទាបដែលមិនអាចទទួលយកបាន ឆ្លងកាត់តាមការវិភាគសង្កេតឃើញថាកុមារជាង២៥% នៅមានសមត្ថភាពអានទាបជាងស្តង់ដា។ នៅក្នុងនោះផងដែរ បើធ្វើការប្រៀបធៀបលទ្ធផលលើមុខវិជ្ជាគណិតវិទ្យានិងវិទ្យាសាស្រ្ត មុខវិជ្ជាអំណានទទួលបានពិន្ទុតិចជាងគេដែលជាបញ្ហាប្រឈមមួយដែលត្រូវដោះស្រាយ (អង្គការខេប, ២០១៧)។ សិស្សានុសិស្សអាចលុបបំបាត់បញ្ហានៃការអាននិងការទទួលបានជំនាញអានស្ទាត់តាំងពីវ័យក្មេងគឺជាគោលដៅចម្បងនៃកម្មវិធីអប់រំ ពីព្រោះការអានស្ទាត់ជំនាញត្រូវបានចាត់ទុកថាជាតម្រូវការចាំបាច់ដែលសិស្សឈានទៅរកការអានយល់ន័យនិងទទួលបានលទ្ធផលសិក្សាល្អលើមុខវិជ្ជាដទៃទៀត (Rasinski, et al., 2005)។ អាស្រ័យហេតុនេះ ដូចបានរៀបរាប់ខាងលើ ការស្រាវជ្រាវនេះនឹងបង្ហាញពីគោលវិធីលំនាំ

បង្រៀនសកម្មភាព **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** ដែលត្រូវយកទៅអនុវត្តន៍លើការអានស្ទាត់របស់សិស្ស កម្រិតបឋមសិក្សាដើម្បីជួយពង្រឹងសមត្ថភាពអំណានរបស់ពួកគេមានភាពប្រសើរឡើងជាងមុន។

## ១.២. បញ្ហានៃការស្រាវជ្រាវ

ក្រសួងអប់រំ យុវជន និងកីឡា បានឯកភាពទៅនឹងលទ្ធផលនៃការអង្កេតទាំងថ្នាក់ជាតិ និង អន្តរជាតិ ដែលក្នុងនោះបានបង្ហាញថា កុមារមួយចំនួនធំជួបការលំបាកក្នុងការអាន និងសរសេរ នៅពេលគេចាប់ផ្តើមរៀនថ្នាក់ដំបូង។ ដើម្បីពង្រឹងសមត្ថភាពសិស្សថែមទៀតលើបំណិនស្គាល់ស្ររ ស្គាល់តួរអក្សរ ចេះផ្សំប្រកបព្យាង្គ ពាក្យ និងចេះវាក្យសព្ទ ឈានទៅសម្រេចគោលបំណងចម្បងគឺ ការអានស្ទាត់និងអានយល់ន័យ (MoEys, 2020)។ ក្នុងអំឡុងកម្មសិក្សាគរុកោសល្យបានសង្កេតឃើញថា សិស្សថ្នាក់ទី៣ មានបញ្ហាក្នុងការអានជាខ្លាំង យោងតាមលទ្ធផលពិន្ទុវាយតម្លៃផ្នែកអំណានជារៀងរាល់ខែ ក្នុងចំណោមសិស្សសរុប៣៨នាក់មានសិស្ស៨នាក់ប៉ុណ្ណោះដែលអាចអានបានស្ទាត់ ចំណែកសិស្ស៣០នាក់ទៀតអានបានតិចតួច ព្រោះពួកគេមានការពិបាកអាន ពាក្យ ល្បះ និង អត្ថបទជាហេតុធ្វើឱ្យពិន្ទុផ្នែកអំណានរបស់ពួកគេមានកម្រិតទាប។ ដើម្បីធ្វើការអានមានភាពប្រសើរឡើងសាលារៀននៅកម្រិតបឋមសិក្សាគួរតែស្វែងយល់ឱ្យកាន់តែច្បាស់អំពីកម្រិតសមត្ថភាពអំណាននិងកំណត់ប្រវត្តិនៃការអានរបស់សិស្សឱ្យបានល្អិតល្អន់។ បញ្ហាខាងលើនឹងត្រូវបានធ្វើការស្រាវជ្រាវប្រតិបត្តិ ដែលមានការរៀបចំជាការធ្វើតេស្តវង្វាយតម្លៃសិស្សមុនចាប់ផ្តើមការបង្រៀន និងក្រោយពេលបញ្ចប់មេរៀនដោយមានការប្រៀបធៀបរវាងការអនុវត្តគោលវិធីលំនាំបង្រៀន សកម្មភាព **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** និង **គ្រាប់តាម** លើអំណានស្ទាត់របស់សិស្សដើម្បីឆ្លើយតបនិងបញ្ហាខាងលើ។

## ១.៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើការកំណត់នូវគោលបំណងនៃការសិក្សា គឺធ្វើការប្រៀបធៀបការអានស្ទាត់របស់សិស្សក្រោយពេលពួកគេទទួលបានការអនុវត្តគោលវិធីលំនាំបង្រៀន

សកម្មភាព **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** ជាមួយនិងគោលវិធីលំនាំបង្រៀនសកម្មភាព**គ្រាប់តាម**។

## ១.៤. សំណួរនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបលើការសិក្សាប្រធានបទខាងលើ អ្នកស្រាវជ្រាវបានរៀបចំសំណួរដូចតទៅ៖

១.ក្រោយពេលអនុវត្តគោលវិធីលំនាំបង្រៀនសកម្មភាព **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** តើការអានស្ទាត់របស់សិស្សមានការប្រែប្រួលដល់កម្រិតណាបើធៀបនិងគោលវិធីលំនាំបង្រៀនសកម្មភាព**គ្រាប់តាម**?

១.១.តើសិស្សមានការពេញចិត្តកម្រិតណាទៅលើការអនុវត្តគោលវិធីលំនាំបង្រៀនសកម្មភាព **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** ?

## ១.៥. សម្មតិកម្ម

ការអានស្ទាត់ដោយប្រើគោលវិធីលំនាំបង្រៀនសកម្មភាព **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** ទទួលបានពិន្ទុខ្ពស់ជាងការប្រើគោលវិធីលំនាំបង្រៀនសកម្មភាព **គ្រាប់តាម**។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះមានសារៈសំខាន់ដូចជា អ្នកស្រាវជ្រាវខ្លួនឯងទទួលមានឯកសារដើម្បីលក្ខខណ្ឌក្នុងការសិក្សាបញ្ចប់ថ្នាក់បរិញ្ញាប័ត្រ និងបទពិសោធក្នុងការបង្រៀន។ ចំពោះលោកគ្រូអ្នកគ្រូនឹងយល់ដឹងកាន់តែច្បាស់អំពីបញ្ហាមួយចំនួនដែលធ្វើឱ្យសិស្សមិនអាចក្លាយខ្លួនជាអ្នកអានដ៏ស្ទាត់ជំនាញបាននិងយកសកម្មភាពបង្រៀនមួយនេះគាំទ្រលើការបង្រៀនឱ្យកាន់តែមានប្រសិទ្ធភាព។ សិស្សានុសិស្សទទួលបានចំណេះដឹងដែលនាំពួកគេឱ្យក្លាយជាអ្នកអានដ៏ស្ទាត់ជំនាញ។ គរុសិស្ស-គរុនិស្សិតជាជំនួយដល់ការសិក្សាស្រាវជ្រាវដែលមានប្រធានបទស្រដៀងនេះ យកធ្វើជាគម្រូនិងឯកសារដើម្បីផ្តល់គំនិតបន្ថែមទៀត។

## ១.៧. ដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាត្រូវបានធ្វើឡើងក្នុងថ្នាក់ទី៣ ក និងថ្នាក់ទី៣ ខ នៃសាលាបឋមសិក្សាពោធិវង្ស ដែលក្នុងនោះមានសិស្សចូលរួមសរុបចំនួន៥២នាក់ ស្រី១៨នាក់ ជ្រើសរើសសំណាកអថេរជន្យ។ រយៈពេលនៃការស្រាវជ្រាវគឺ ១០សប្តាហ៍អំឡុងកម្មសិក្សាគរុកោសល្យ។ លទ្ធផលនៃការសិក្សាផ្តោតសំខាន់ទៅលើការអនុវត្តគោលវិធីលំនាំបង្រៀនសកម្មភាព **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** ទៅលើការបង្រៀនមេរៀនអំណាន (ការអានស្ទាត់) ដល់សិស្សថ្នាក់ទី៣។

## ១.៨. ការពន្យល់បញ្ញត្តិសំខាន់ៗ

សកម្មភាពបង្រៀន **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** គឺជាយុទ្ធសាស្ត្របង្រៀនមួយដែលរួមមានការបង្ហាញនិងការអនុវត្ត។ ដំណាក់កាលខ្ញុំធ្វើ៖ គ្រូបង្រៀនមានសកម្មភាពលេចធ្លោក្នុងតួនាទីនាំសិស្សអនុវត្តតាមសកម្មភាពនីមួយៗ។ ដំណាក់កាលយើងធ្វើ៖ នៅពេលសិស្សចាប់ផ្តើមទទួលបានព័ត៌មានពីខ្លឹមសារមេរៀនរួចគឺពួកគេត្រូវការអនុវត្តសកម្មទាំងនោះសាឡើងវិញជាមួយគ្រូ។ ដំណាក់កាលអ្នកធ្វើ៖ ពួកគេពឹងផ្អែកលើខ្លួនឯងនិងមានទំនួលខុសត្រូវកាន់តែច្រើនហើយអាចអនុវត្តសកម្មភាពខាងដើមបានយ៉ាងរលូន (Levy, 2007)។

**ការអានស្ទាត់** គឺសំដៅដល់សមត្ថភាពអានរបស់សិស្សក្នុងការអានបានត្រឹមត្រូវក្នុងល្បឿនសមរម្យនិងមានការលើកដាក់សំឡេងតាមសញ្ញាសម្ព័ន្ធ។ក្នុងការអាននេះទៀតសោតគឺតម្រូវឱ្យសិស្សអានពាក្យច្បាស់ៗដោយមិនមានការរអាក់រអួលទៅលើការប្រកបនោះឡើយ (Timothy & Rasinski, 2004)។ ក្នុងការសិក្សាប្រធានបទមួយនេះអ្នកស្រាវជ្រាវបានកំណត់យកនិយមន័យមួយនេះដើម្បីជួយគាំទ្រដល់ការពិសោធសកម្មភាពបង្រៀនរបស់ខ្លួន។

# ជំពូកទី២

# ទិដ្ឋភាពទូទៅ

## ២.១. និយមន័យពាក្យគន្លឹះ

### ២.១.១. ខ្ញុំធ្វើ យើងធ្វើ និងអ្នកធ្វើ

ជាគោលការណ៍បង្រៀននិងដ៏សំខាន់ដែលធានានូវការចូលរួមរបស់សិស្សក្នុងសកម្មភាពរៀនប្រកបដោយទំនុកចិត្តនិងមោទនភាព។ វាគឺជាការបង្រៀនបំណិនថ្មីដោយផ្ទេរការទទួលខុសត្រូវដល់សិស្សបន្តិចម្តងៗតាមរយៈការអនុវត្តជាជំហានៗដោយមានការជួយគាំទ្រដល់ដំណើរការនៃការរៀន (MoEYS, 2019) ។

### ២.១.២. ការចេះអានស្ទាត់

សំដៅដល់ការបង្រៀនដែលជួយពង្រឹងសមត្ថភាពអានបានត្រឹមត្រូវក្នុងល្បឿនសមស្របនិងមានការលើកដាក់សំឡេង។ ប្រសិនបើសិស្សអានយឺតពេក ហើយរវល់តែប្រកបពាក្យនីមួយៗ គេនឹងភ្លេចន័យពាក្យនោះ នៅពេលអានល្បះចប់ (MoEYS, 2019)។

## ២.២. លក្ខណៈទូទៅនៃការបង្រៀនអំណាន

នៅឆ្នាំ២០១០ ក្រសួងអប់រំ យុវជននិងកីឡា បានធ្វើការកែសម្រួលសៀវភៅភាសាខ្មែរថ្នាក់ទី១ដល់ទី៣ហើយត្រូវបានដាក់ឱ្យប្រើប្រាស់នៅឆ្នាំ២០១១ចំពោះសៀវភៅភាសាខ្មែរថ្នាក់ទី១និងឆ្នាំ២០១២សម្រាប់សៀវភៅភាសាខ្មែរថ្នាក់ទី២និងទី៣។ មូលហេតុដែលមានការកែតម្រូវនេះឡើងគឺដើម្បីអភិវឌ្ឍនូវលទ្ធភាពនៃការអានរបស់សិស្សឱ្យមានភាពប្រសើរឡើងជាងមុន។ ដើម្បីឱ្យការបង្រៀនអំណានប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពត្រូវអនុវត្តន៍តាមដំណាក់កាលនៃសមាសភាគអំណានទាំង៥មានដូចជា ការស្គាល់សូរ ការស្គាល់តួអក្សរនិងសូរ ការចេះវាក្យសព្ទ ការចេះអានស្ទាត់ ការអានដើម្បីយល់ន័យ (MoEYS, 2019)។

## ២.៣. ការអនុវត្តគោលវិធីលំនាំបង្រៀនសកម្មភាព ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ

នៅជំហានដំបូងគ្រូប្រើប្រាស់ជំនាញរបស់ខ្លួនដើម្បីធ្វើជាគម្រូដល់សិស្សគ្រប់ៗគ្នា។ ប្រសិនជាសិស្សមិនដឹងពីរបៀបក្នុងការអាន គ្រូត្រូវអានបង្ហាញដល់សិស្សដោយមានភាពហ្មត់ចត់ និងច្បាស់លាស់។ ក្នុងដំណាក់កាលមួយនេះគឺតម្រូវឱ្យសិស្សមានការយកចិត្តទុកដាក់រាល់ពេលគ្រូបង្រៀនបានបង្ហាញសកម្មភាពណាមួយទៅកាន់ពួកគេបើពុំដូច្នោះទេពួកគេមិនដឹងពីមិនទទួលបានចំណេះដឹងទៅលើការបង្ហាញរបស់គ្រូឡើយ។ ជំហានបន្ទាប់មកទៀតគ្រូឱ្យសិស្សអនុវត្តសាកល្បងជាដៃគូ(ដៃគូជាមួយគ្រូឬមិត្តរួមថ្នាក់)ហើយមានការធ្វើសកម្មភាពកាន់តែស៊ីជម្រៅ។ ជំហាននេះតម្រូវឱ្យគ្រូបង្រៀនដឹកនាំនិងលើកទឹកចិត្តសិស្សគ្រប់ពេលដើម្បីឱ្យពួកគេយកចិត្តទុកដាក់លើសកម្មភាពដែលពួកគេកំពុងសិក្សារួមផ្សំជាមួយការបន្ថែមទៅលើសម្ភារៈបង្រៀនជំនួយផងដែរ។ ការធ្វើបែបនេះជួយបង្កើតទំនុកចិត្តដល់សិស្សដែលមានភាពអៀនខ្មាស និងសិស្សដែលពិការភាពទៀតផង។ សកម្មភាពមួយនេះក៏បានបង្កើតទំនុកចិត្តសម្រាប់សិស្សដែលមានពិការភាពក្នុងការសិក្សារៀនសូត្រ កុមារ**Autism** ជាដើម។ ក្រោយពីបានអនុវត្តសកម្មភាព **ខ្ញុំធ្វើនិងយើងធ្វើ** រួចមកសិស្សអាចឈានទៅដល់ដំណាក់កាលមួយទៀតគឺ**អ្នកធ្វើ**។ សកម្មភាពចុងក្រោយនេះបានបង្ហាញពីទំនួលខុសត្រូវខ្ពស់របស់សិស្សដែលពួកគេត្រូវមានការយកចិត្តទុកដាក់ក្នុងការអនុវត្តអំណានខ្លួនឯងដោយមានភាពជឿជាក់និងស្វាហាប់ជាទីបំផុត។ ដំណាក់កាលនេះអាចប្រើប្រាស់បាននៅពេលគ្រូត្រូវការធ្វើតេស្តសាកល្បងលើចំណេះដឹងរបស់សិស្សលើផ្នែកអំណាន (McCoy, 2011)។

## ២.៤. លទ្ធផលតេស្តវាយតម្លៃ PISA2018

យោងតាមប្រសាសន៍លោកបណ្ឌិតសភាចារ្យ **ហង់ ជួនណារ៉ុន** បានបង្ហាញថាតាមរយៈការវាយតម្លៃលើសិស្សអាយុ១៥ឆ្នាំនៅកម្ពុជាមានសមត្ថភាពខ្ពស់ជាងបើធៀបជាមួយសិស្សប្រទេស **Senegal**និងប្រទេសសំប៊ី។ ផ្អែកលើលទ្ធផល **PISA-D**បានបង្ហាញថាពិន្ទុលើគ្រប់មុខវិជ្ជាទាំងអស់សិស្សនៅកម្ពុជាមានសមត្ថភាពប្រហាក់ប្រហែលនិងសិស្សបណ្តាប្រទេសដែលបានចូលរួមវាយតម្លៃលើការសិក្សាក្នុងកម្មវិធីអន្តរជាតិសម្រាប់ប្រទេសដែលកំពុងអភិវឌ្ឍន៍។ លើកលែងតែមុខវិជ្ជា

អំណានសិស្សនៅកម្ពុជាមានសមត្ថភាពទាបជាងបណ្តាប្រទេសជាសមាជិក**PISA-D**និងប្រទេសជាសមាជិកអាស៊ាន។ កម្ពុជាបានចូលជាសមាជិកគម្រោងនៅឆ្នាំ២០១៦ដែលផ្តើមឡើងរបស់អង្គការ**OECD**និងដៃគូអភិវឌ្ឍមួយចំនួនកម្មវិធីមានឈ្មោះថា **PISA-D** (ជួនណារ៉ុន, ២០១៨) ។

## ២.៥. ការវាស់វែងការអានស្ទាត់របស់សិស្ស

ការសិក្សានេះត្រូវបានធ្វើឡើងដើម្បីសង្កេតមើលពីភាពត្រឹមត្រូវនៃការអានរបស់សិស្សនិងការផ្លាស់ប្តូរនៅពេលពួកគេអានអត្ថបទ។ យោងតាមការសិក្សាស្រាវជ្រាវរបស់ **CJES** បានបង្ហាញពីការវាស់វែងកម្រិតនៃការអានរបស់សិស្សដោយផ្តោតសំខាន់ពីភាពខុសគ្នារវាងសិស្សអានស្ទាត់ជំនាញនិងសិស្សអានមិនស្ទាត់ជំនាញ។ ក្នុងនោះគាត់បានបែងចែកអត្ថបទជា៣ផ្នែក និងមានការរៀបចំផ្នែកដោយលម្អិត។ ទី១ គឺត្រូវមានគ្រូបន្ទុកថ្នាក់ឬអ្នកជំនាញផ្នែកអំណាន។ ទី២ គឺការប្រើប្រាស់ម៉ាស៊ីនថតសំឡេងដើម្បីប្រាកដថាសិស្សអានអត្ថបទដោយផ្ទាល់មាត់។ ទី៣ គឺយកសំឡេងទាំងនោះមកស្តាប់ឡើងវិញដើម្បីដឹងពីចំនួនពាក្យដែលសិស្សអានត្រឹមត្រូវ និងអានមិនត្រឹមត្រូវ។ ចំពោះការកត់ការអានផ្ទាល់មាត់នីមួយៗនៃចំណែកទាំង៣របស់អត្ថបទខាងលើត្រូវបានស្តាប់ចេញពីឧបករណ៍ថតសំឡេងម្តងហើយម្តងទៀតដើម្បីទទួលបានភាពត្រឹមត្រូវនៃការអាននិងអត្រានៃការអាន **WCPM**(ពាក្យត្រឹមត្រូវក្នុងមួយនាទី) ដែលជាវិធីសាស្ត្រក្នុងការវាយតម្លៃផ្អែកលើកម្មវិធីដែលបង្កើតឡើងដោយលោក **Deno (1985)** (Bastug, Keskin, & Akyol, 2017)។ ផ្អែកលើការស្រាវជ្រាវរបស់លោក**Killgallon** បានបង្ហាញថា នៅពេលសិស្សបានត្រឹមតែស្តាប់ការអានរបស់គ្រូការបញ្ចេញសំឡេងបានត្រឹមត្រូវយ៉ាងតិច៩០%នៃពាក្យពិបាក (**គ្រូអានជាគម្រូ**) ។ ប្រសិនបើពួកគេបានធ្វើការអនុវត្តការអានជាមួយគ្រូ ការបញ្ចេញសំឡេងទៅលើពាក្យក្នុងអត្ថបទបានត្រឹមត្រូវ៩៥%នៃពាក្យពិបាក(**គ្រូនិងសិស្សអានរួមគ្នា**)។ ក្រោយពីការអនុវត្តសកម្មភាពទាំងពីរខាងលើរួចមកសិស្សអាចបញ្ចេញសំឡេងទៅលើពាក្យក្នុងអត្ថបទបានត្រឹមត្រូវ៩៨%នៃពាក្យពិបាកដោយការអានឯករាជ្យ(**សិស្សធ្វើ**) (Killgalon, 1942)។

ការអប់រំនៅក្នុងសាលារដ្ឋត្រូវបានអនុវត្តនៅក្នុងប្រទេសTurkeyបង្រៀនជាភាសាTurkey ប៉ុន្តែនៅក្នុងប្រទេសមួយនេះក៏មានភាសាកំណើតរបស់ខ្លួនដែរគឺKurdish ។ សិស្សនៅទីនោះគឺត្រូវសិក្សាពីរភាសាផងដែរ ជាហេតុធ្វើឱ្យពួកគេមានបញ្ហាលើការអានជាខ្លាំង។ ក្នុងនោះផងដែរមានការសិក្សាមួយបានផ្តោតសំខាន់ទៅលើការអានស្ទាត់ជំនាញនិងមិនស្ទាត់ជំនាញរបស់សិស្សកម្រិតបឋមសិក្សាថ្នាក់ទី៤។ ក្នុងការសិក្សាមួយនេះគេបានកំណត់គោលបំណង២គឺ ទីមួយ៖ កំណត់ភាពខុសគ្នានៃពិន្ទុរបស់សិស្សថ្នាក់ទី៤ទៅលើការអានភាសាTurkey និងភាសាKurdish។ ទីពីរ៖ ធ្វើការវាយតម្លៃពីអត្រានៃការអានមានកំហុស ការអានបានត្រឹមត្រូវ របស់សិស្សទៅលើភាសាទាំងពីរថាមួយណាប្រសើរជាងមួយណា។ ការស្រាវជ្រាវបានធ្វើឡើងនៅសាលាបឋមសិក្សាមួយនៅខេត្ត Tusba ក្នុងតំបន់ Van នៅក្នុងឆ្នាំសិក្សា២០១៧-២០១៨។ ចំពោះការវាស់វែងលើការអានពាក្យគឺដោយសិស្សត្រូវអានឱ្យបានយ៉ាងតិច១០០ពាក្យក្នុងរយៈពេលមួយនាទី។ ពិន្ទុដែលចាត់ទុកថាជាអ្នកអានស្ទាត់ជំនាញគឺចាប់ពី១៦ពិន្ទុឡើងទៅ ឯពិន្ទុដែលចាត់ទុកថាជាអ្នកអានមិនស្ទាត់ជំនាញគឺចាប់ពី៥ពិន្ទុចុះក្រោម។ មុនពេលដំណើរការអាន សិស្សត្រូវបានផ្តល់រយៈពេល២៥ទៅ៣០នាទីដើម្បីធ្វើការត្រៀមខ្លួន។ គំរូសំណាកមានសិស្សចូលរួមចំនួន៤២៨នាក់ ស្រី២០១នាក់។ យោងតាមលទ្ធផលពិន្ទុរបស់សិស្សទៅលើការអានភាសាទាំង២បានបង្ហាញថា ភាសាTurkeyសិស្សអានបានចំនួន៣៩.៧% រីឯភាសាKurdish សិស្សអានបានចំនួន៦០.៣%។ ក្នុងនោះសិស្សប្រុសកម្រិតនៃការអានបាន៥៣% ចំណែកសិស្សស្រីកម្រិតនៃការអានបាន៤៧%។ ផ្អែកលើលទ្ធផលពិន្ទុខាងលើបានបង្ហាញថា កម្រិតនៃការអានស្ទាត់ជំនាញភាសាKurdishមានភាពប្រសើរជាងភាសាTurkey ហើយសិស្សប្រុសមានការអានបានស្ទាត់ជំនាញជាងសិស្សស្រីផងដែរ (KiziItas & Yildiz, 2020)។

ការសិក្សាស្រាវជ្រាវរបស់ Nina Chiulan Lin និង Hsiao-fang Cheng (2021) ផ្តោតសំខាន់លើប្រសិទ្ធភាពនៃគោលវិធីលំនាំបង្រៀនសកម្មភាព **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** មានករណីសិក្សាមួយចំនួនដូចជា៖ យោងតាមការស្រាវជ្រាវនៅប្រទេសកាណាដា ក្នុងការបង្រៀនការអានយល់ន័យ

ភាសាអង់គ្លេសសម្រាប់សិស្សអ៊ីរ៉ាក់ដែលមិនមែនម្ចាស់ដើម។ ការសិក្សាផ្តោតចំពោះសិស្សថ្នាក់ទី៦ មានអាយុ១១ទៅ១២ឆ្នាំនិងមានចំនួន៨០នាក់បានចូលរួម។ លទ្ធផលនៃការស្រាវជ្រាវនេះបាន បង្ហាញថាអ្នកចូលរួមរហូតដល់៩៨.៧៥% តាមរយៈការធ្វើកម្រងសំណួរស្ទង់មតិរបស់សិស្ស។ យ៉ាង ណាមិញចំពោះការសិក្សានៅប្រទេសអ៊ីរ៉ាក់ បង្ហាញពីមធ្យមភាគនៃការធ្វើតេស្តចុងក្រោយបានឱ្យ ឃើញពីភាពខុសគ្នាគឺក្រុមពិសោធន៍មានមធ្យមភាគ៣៣.៣ រីឯក្រុមមួយទៀតមានមធ្យមភាគត្រឹម តែ២៥.២ តាមលទ្ធផលនេះធ្វើឲ្យអ្នកស្រាវជ្រាវរូបនេះសន្និដ្ឋានបានថាការប្រើប្រាស់គោលវិធី បង្រៀនខាងលើពិតជាមានប្រសិទ្ធភាពក្នុងការបង្រៀនលើផ្នែកអំណាន (Yaseen, 2018)។

# ជំពូកទី៣

# វិធីសាស្ត្រនៃការស្រាវជ្រាវ

## ៣.១. វិធីសាស្ត្រ

ការសិក្សាលើប្រធានបទ **ការប្រើប្រាស់គោលវិធីលំនាំបង្រៀនសកម្មភាព ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ ដើម្បីជួយសិស្សក្នុងការអានស្ទាត់លើមុខវិជ្ជាភាសាខ្មែរ** ត្រូវបានផ្ដោតលើការសិក្សាតាមបែបបរិមាណវិស័យ(**ការពិសោធពីរក្រុមផ្សេងគ្នា**)ដោយប្រើប្រាស់នូវកម្រងតេស្តមុនពេលបង្រៀននិងក្រោយពេលបង្រៀនសម្រាប់សិស្សក្នុងការប្រមូលទិន្នន័យជាក់ស្ដែង។ អថេរនៃការស្រាវជ្រាវមាន២ គឺ អថេរឯលរាជ្យ៖ ការប្រើប្រាស់គោលវិធីលំនាំបង្រៀនសកម្មភាព ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ និងអថេរមិនឯករាជ្យ៖ ជួយសិស្សក្នុងការអានស្ទាត់លើមុខវិជ្ជាភាសាខ្មែរ។

## ៣.២. គំរូគំរូនិងវិធីនៃការជ្រើសរើស

នៅក្នុងប្រធានបទខាងលើត្រូវបានជ្រើសរើសសំណាកតាមបែបបរិមាណវិស័យ។ សំណាកធ្វើការប្រមូលតាមរយៈបុរេតេស្ត ដោយជ្រើសរើសសិស្សពីថ្នាក់ទី៣ ក និងថ្នាក់ទី៣ ខនៃសាលាបឋមសិក្សាពោធិវង្ស ។ សំណាកដែលបានចូលរួមទាំងអស់គឺជ្រើសយកត្រឹមតែ៥២សំណាកប៉ុណ្ណោះដែលមានសមត្ថភាពប្រហាក់ប្រហែលគ្នាដើម្បីយកមកធ្វើការពិសោធ ដោយបែងចែកជា២ក្រុមស្មើគ្នា។ វិធីក្នុងការជ្រើសរើសសិស្សតាមរយៈតារាងបញ្ជីឈ្មោះសិស្សលេខរៀងសេសនៅក្នុងក្រុមទី១ ទទួលបានការអនុវត្តសកម្មភាពបង្រៀន **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** និងលេខរៀងគូក្រុមទី២ទទួលបានការអនុវត្តសកម្មភាពបង្រៀន**គ្រាប់តាម**។ ក្រោយប្រើប្រាស់គោលវិធីលំនាំបង្រៀនសកម្មភាពទាំងពីររួច អ្នកស្រាវជ្រាវនឹងដាក់ **តេស្តចុងកាល** ដើម្បីយកលទ្ធផលពិន្ទុទៅធ្វើការវិភាគថាមួយណាមានភាពប្រសើរជាងមួយណា។

## ៣.៣. ទីតាំងនៃការស្រាវជ្រាវ

ទីតាំងសិក្សាស្រាវជ្រាវត្រូវបានជ្រើសរើសសាលាបឋមសិក្សាពោធិវង្ស មានទីតាំងភូមិចំការសំរោង២ សង្កាត់ចំការសំរោង ក្រុងបាត់ដំបង ខេត្តបាត់ដំបង។

## ៣.៤. ឧបករណ៍នៃការស្រាវជ្រាវ

ដើម្បីសម្រេចគោលបំណងទាំងនេះឧបករណ៍ស្រាវជ្រាវមួយចំនួនត្រូវបានបង្កើតឡើងដូចជា(១) កម្រងតេស្តដើមកាលនិងចុងកាល ត្រូវបានចែកជាពីរគឺ ផ្នែកទី១៖ ព័ត៌មានទូទៅរបស់សិស្ស ផ្នែកទី២៖ កម្រងសំណួរ(អត្ថបទនិងនីតិវិធីនៃការដាក់ពិន្ទុ) (២)កម្រងសំណួរស្ទង់មតិ ត្រូវបានចែកជាពីរគឺ ផ្នែកទី១៖ ស្ថានភាពទូទៅរបស់សិស្ស ផ្នែកទី២៖ ជ្រើសចម្លើយ(១.មិនយល់ស្របគ្រប់យ៉ាង ២.មិនយល់ស្រប ៣.មិនទាន់សម្រេចចិត្ត ៤.យល់ស្រប ៥.យល់ស្របគ្រប់យ៉ាង)។

## ៣.៥. វិធីសាស្ត្រប្រមូលទិន្នន័យ

ការសិក្សាខាងលើត្រូវបានប្រមូលទិន្នន័យតាមរយៈការប្រើប្រាស់ម៉ោងអំណានភាសាខ្មែរជាក់ស្តែង ដោយមានការបែងចែកសិស្សជា២ក្រុមគឺ (១)ការអនុវត្តលើគោលវិធីលំនាំបង្រៀនសកម្មភាព **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** (២)ការអនុវត្តលើគោលវិធីលំនាំបង្រៀនសកម្មភាពទូទៅ(គ្រាប់តាម)។ នៅពេលចាប់ផ្តើមបង្រៀននៃក្រុមទាំងពីរ អ្នកស្រាវជ្រាវបានដាក់តេស្តដើមកាលដើម្បីធ្វើការបែងចែកឱ្យមានតម្លាភាពនៃកម្រិតចំណេះដឹងរបស់សិស្សក្នុងក្រុមនីមួយៗ។ ក្រោយបញ្ចប់ការបង្រៀន អ្នកស្រាវជ្រាវបានដាក់តេស្តចុងកាលដើម្បីស្រង់ទិន្នន័យ(ពិន្ទុ)ពីក្រុមទាំងពីរយកមកវិភាគបកស្រាយសំណាកដែលបានប្រមូល។

## ៣.៦. ការវិភាគទិន្នន័យ

ក្នុងដំណើរការរៀបចំទិន្នន័យអ្នកស្រាវជ្រាវត្រូវបញ្ចូលលទ្ធផលពិន្ទុរបស់សិស្ស(ទិន្នន័យ) ក្នុងកម្មវិធី ដើម្បីរកមធ្យម គម្លាតស្តង់ដារនិង នៃពិន្ទុរបស់ក្រុមនីមួយៗ។ ជាក់ស្តែងអ្នកស្រាវជ្រាវត្រូវយកពិន្ទុដែលបានមកពីការដាក់**តេស្តដើមកាលនិងតេស្តចុងកាល**ទៅការបង្រៀនអំណានស្ទាត់តាម

គោលវិធីលំនាំបង្រៀនសកម្មភាព **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** និង**ត្រាប់តាម។** បន្ទាប់មកអ្នកស្រាវជ្រាវធ្វើការវិភាគទិន្នន័យដើម្បីរក **p-value** ក្នុងកម្មវិធី **Microsoft Excel (Paired sample t-test & Independent sample t-test)**។ បន្ទាប់ពីរកបានតម្លៃ **p-value** អាចបកស្រាយទិន្នន័យដោយច្រានចោលសម្មតិកម្មណាមួយ **(Ho&Ha)**។ កំណត់ $\mathbf{p < 0.01}$ និង**សម្មតិកម្ម** គឺការអានស្ទាត់ដោយប្រើគោលវិធីលំនាំបង្រៀនសកម្មភាព **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** ទទួលបានពិន្ទុខ្ពស់ជាងការប្រើគោលវិធីលំនាំបង្រៀនសកម្មភាព **ត្រាប់តាម**។

## ៣.៧. ក្រមសីលធម៌ស្រាវជ្រាវ

ចំពោះក្រមសីលធមិនៃការស្រាវជ្រាវ អ្នកស្រាវជ្រាវត្រូវមានជាលិខិតស្នើសុំធ្វើការប្រមូលទិន្នន័យដល់នាយកសាលានិងរៀបចំជាលិខិតស្នើសុំប្រមូលទិន្នន័យសម្រាប់អ្នកចូលរួមពិសេស។ បន្ទាប់មកអ្នកស្រាវជ្រាវត្រូវប្រាប់ពីគោលបំណងនៃការស្រាវជ្រាវ ប្រធានបទនិងគម្រោងដែលត្រូវចុះអនុវត្តការ។ ម្យ៉ាងវិញទៀតអ្នកស្រាវជ្រាវត្រូវមានអាកប្បកិរិយាសមរម្យ មានសីលធមិគោរពនិងឱ្យតម្លៃដល់លោកគ្រូអ្នកគ្រូដែលស្ថិតនៅក្នុងសាលាសហការ។លើសពីនេះទៅទៀត រាល់ទិន្នន័យឬឯកសារមិនត្រូវចម្លងដោយមិនមានការអនុញ្ញាត ព្រោះអាចជាអំពើសាប់ចោរកម្ម។

# ជំពូក៤

# លទ្ធផលនៃការស្រាវជ្រាវ

## ៤.១.លទ្ធផលនៃការដាក់តេស្ត

ខាងក្រោមនេះគឺជាការបង្ហាញលទ្ធផលនៃការធ្វើតេស្តស្ថិតិ ដែលត្រូវបានប្រើដើម្បីប្រៀបធៀបពិន្ទុខុសៗគ្នាពីការធ្វើតេស្តអំណាន។ ការវិភាគបានឡើងដើម្បីបង្ហាញពីភាពខុសគ្នារវាងក្រុមអនុវត្តន៍សកម្មភាពបង្រៀន **គ្រាប់តាម** និងក្រុម **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** ។

**តារាង១ ការប្រៀបធៀបបលទ្ធផលតេស្តសិស្សថ្នាក់ទី៣ មុនពេលនិងក្រោយពេលរៀនរបស់ក្រុមគ្រាប់តាម**

| តេស្ត | សំណាក | មធ្យម | គម្លាតស្តង់ដារ | ផលដកមធ្យម | តេស្តស្ថិតិ | ប្រូបាបប៊ីលីតេ |
|---|---|---|---|---|---|---|
| មុនពេល | **26** | **28.92** | **10.04** | **8.50** | **5.91** | **0.00** |
| ក្រោយពេល | **26** | **37.42** | **13.48** | | | |

**p<.01**

តារាង១ បង្ហាញថាមុនពេលប្រើប្រាស់គោលវិធីលំនាំបង្រៀនសកម្មភាព**គ្រាប់តាម** សិស្សទទួលបានពិន្ទុមធ្យម $\bar{x}$**=28.92** **(SD=10.0**4) រីឯក្រោយពេលបង្រៀនសិស្សទទួលបានពិន្ទុមធ្យម $\bar{x}$=37.42 (SD=13.48) ។ តេស្តស្ថិតិ t-test (t=5.91, p-value=0.00) បង្ហាញថាមធ្យមពិន្ទុរបស់សិស្សមុនពេលនិងក្រោយពេលប្រើប្រាស់គោលវិធីលំនាំសកម្មភាពគ្រាប់តាមមានភាពខុសគ្នា ពោលគឺពិន្ទុក្រោយពេលខ្ពស់ជាងពិន្ទុមុនពេលបង្រៀន ដោយអចៃដន្យក្នុងលំដាប់ .01 ។

តារាង២ ការប្រៀបធៀបបលទ្ធផលតេស្តសិស្សថ្នាក់ទី៣ មុនពេលនិងក្រោយពេលរៀនរបស់ក្រុមខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ

| តេស្ត | សំណាក | មធ្យម | គម្លាតស្តង់ដារ | ផលដកមធ្យម | តេស្តស្ថិតិ | ប្រូបាបប៊ីលីតេ |
|---|---|---|---|---|---|---|
| មុនពេល | **26** | **28.92** | **10.04** | **20.54** | **9.70** | **0.00** |
| ក្រោយពេល | **26** | **49.46** | **16.89** | | | |

**p<.01**

តារាង២ បង្ហាញថាមុនពេលប្រើប្រាស់គោលវិធីលំនាំបង្រៀនសកម្មភាព **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** សិស្សទទួលបានពិន្ទុមធ្យម $\bar{x}$**=28.92 (SD=10.0**4) រីឯក្រោយពេលបង្រៀនសិស្សទទួលបានពិន្ទុមធ្យម $\bar{x}$=49.46 (SD=16.89) ។ តេស្តស្ថិតិ t-test (t=9.70, p-value=0.00) បង្ហាញថាមធ្យមពិន្ទុរបស់សិស្សមុនពេលនិងក្រោយពេលប្រើប្រាស់គោលវិធីលំនាំសកម្មភាព**ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** មានភាពខុសគ្នា ពោលគឺពិន្ទុក្រោយពេលខ្ពស់ជាងពិន្ទុមុនពេលបង្រៀន ដោយអថេរជន្យក្នុងលំដាប់ .01 ។

តារាង៣ ការប្រៀបធៀបបលទ្ធផលតេស្តចុងកាលរវាងក្រុមត្រាប់តាម និង ក្រុម ខ្ញុំធ្វើ យើងធ្វើអ្នកធ្វើ

| ក្រុម | សំណាក | មធ្យម | គម្លាតស្តង់ដារ | ផលដកមធ្យម | តេស្តស្ថិតិ | ប្រូបាបប៊ីលីតេ |
|---|---|---|---|---|---|---|
| **ត្រាប់តាម** | **26** | **37.42** | **13.48** | **12.04** | **2.84** | **0.006** |
| **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** | **26** | **49.46** | **16.89** | | | |

**p<.01**

តារាង៣ បង្ហាញថាមុនពេលប្រើប្រាស់គោលវិធីលំនាំបង្រៀនសកម្មភាព**ត្រាប់តាម** សិស្សទទួលបានពិន្ទុមធ្យម $\bar{x}$**=37.42 (SD=13.48**) រីឯមុនពេលប្រើប្រាស់គោលវិធីលំនាំបង្រៀនសកម្មភាព **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ**សិស្សទទួលបានពិន្ទុមធ្យម $\bar{x}$**=49.46 (SD=16.89**) ។ តេស្តស្ថិតិ t-test (t=2.84, p-value=0.006) បង្ហាញថាមធ្យមពិន្ទុរបស់សិស្សក្រោយពេលរៀនដោយប្រើប្រាស់គោលវិធីលំនាំ

បង្រៀនសកម្មភាព**ត្រាប់តាម និងខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** មានភាពខុសគ្នា ពោលគឺពិន្ទុក្រោយពេលរបស់ក្រុម**ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** ខ្ពស់ជាងពិន្ទុក្រោយពេលរៀនរបស់ក្រុម**ត្រាប់តាម** ដោយអចៃដន្យក្នុងលំដាប់ .01 ។




ក្រាហ្វទី១៖ លទ្ធផលការប្រៀបធៀបនៃមធ្យមភាគតេស្តមុនពេលនិងក្រោយពេលបង្រៀនរបស់ក្រុម **ត្រាប់តាម** និង **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** ។ បានបង្ហាញថា ក្រុម **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** មានមធ្យមភាគខ្ពស់ជាងក្រុម **ត្រាប់តាម** ។

## ៤.២. លទ្ធផលនៃការគម្រងសំណួរស្ទង់មតិ

ផ្នែកនេះគឺជាការតេស្តស្ទង់មតិសាកល្បងដើម្បីដឹងថាសិស្សមានការពេញចិត្តទៅលើសកម្មភាពដែលបានអនុវត្តន៍របស់គ្រូបង្រៀនចំពោះថ្នាក់រៀនដល់កម្រិតណា។ (Shamsul, 2014)

តារាង៤ លទ្ធផលកម្រងសំណួរស្ទង់មតិទៅលើសិស្សដែលទទួលបានការអនុវត្តលំនាំបង្រៀនសកម្មភាព ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ

| ល.រ | ខ្លឹមសារ | មធ្យមភាគ | គម្លាតស្តង់ដារ |
|---|---|---|---|
| ១ | ការអានរបស់ខ្ញុំរីកចម្រើនជាងមុនក្រោយពេលរៀនអានដោយអនុវត្តតាមគ្រូ អានជាមួយគ្រូ ជាក្រុម និងអានដោយខ្លួនឯង។ | 4.62 | 0.50 |
| ២ | ខ្ញុំចាំបានច្រើននូវពេលបានស្តាប់គ្រូអាន ចូលរួមអានជាមួយគ្រូ និងអានដោយខ្លួនឯង។ | 4.60 | 0.51 |
| ៣ | ខ្ញុំដឹងពីរបៀបអាន ប្រកបពាក្យ អានល្បះ និងអត្ថបទបានកាន់តែប្រសើរនៅពេលសង្កេតពីរបៀបអានរបស់គ្រូ អានជាមួយគ្រូ និងអានដោយខ្លួនឯង។ | 4.69 | 0.48 |
| ៤ | ខ្ញុំគិតថាការអានដោយស្តាប់គ្រូជាគម្រូ អានជាមួយគ្រូ និងអានបន្ថែមដោយខ្លួនឯង ធ្វើឱ្យខ្ញុំមានការប្រុងប្រយ័ត្ននិងស្គាល់ពាក្យទាំងនោះកាន់តែច្បាស់។ | 4.54 | 0.50 |
| ៥ | ខ្ញុំចូលចិត្តរៀននៅពេលគ្រូផ្សំប្រកបពាក្យឬអានឱ្យជាគម្រូមុន ជាដៃគូ និងហ្វឹកហាត់អានរៀងៗខ្លួន។ | 4.50 | 0.51 |
| **ពិន្ទុមធ្យម** | | 4.59 | 0.50 |

តារាង៤ បង្ហាញពីលទ្ធផលពីផ្នែក ២ នៃកម្រងសំណួរការពេញចិត្តរបស់សិស្ស ដែលកម្រិតពិន្ទុទាំង៥ប្រភេទគឺ (១.មិនយល់ស្របទាំងស្រុង ២.មិនយល់ស្រប ៣.មិនទាន់សម្រេចចិត្ត ៤.យល់ស្រប ៥.យល់ស្របទាំងស្រុង)។ ការបង្ហាញពិន្ទុមធ្យមសរុបនៃចំណុចទាំង5 គឺ $\bar{X}$=4.59 (SD=0.50) ដែលបង្ហាញថាសិស្សក្រុមពិសោធន៍ជារួមគឺ **យល់ស្រប** ជាមួយសកម្មភាពបង្រៀន **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** ក្នុងថ្នាក់រៀននេះ។

## ៤.២.ការពិភាក្សា

យោងតាមលទ្ធផល និងការបកស្រាយទិន្នន័យនីមួយៗ នៃការពិសោធលើប្រធានបទ **ការប្រើប្រាស់គោលវិធីលំនាំបង្រៀនសកម្មភាព ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ ដើម្បីជួយសិស្សក្នុងការអានស្ទាត់**

**លើមុខវិជ្ជាភាសាខ្មែរ** បានបង្ហាញឱ្យឃើញថា ការបង្រៀនដោយប្រើប្រាស់គោលវិធីលំនាំបង្រៀនសកម្មភាព **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ**មានសិស្សទទួលបានពិន្ទុខ្ពស់ជាងការបង្រៀនដោយប្រើប្រាស់គោលវិធីលំនាំបង្រៀនសកម្មភាព**គ្រាប់តាម**។ ពោលគឺប្រសិទ្ធភាពការអានស្ទាត់របស់ក្រុម **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ**ទទួលបាន៦៦% រីឯក្រុម **គ្រាប់តាម** ទទួលបាន៥០%។ តាមរយៈកម្រងសំណួរស្ទង់មតិគឺបញ្ជាក់ឱ្យឃើញថាសិស្សយល់ស្របលើគោលវិធីលំនាំបង្រៀនសកម្មភាព **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** នេះ។ លទ្ធផលកម្រងសំណួរស្ទង់មតិលើក្រុមពិសោធន៍ទទួលបាន ៩១.៨%។

ក្នុងការស្រាវជ្រាវនៃប្រធានបទ គឺអ្នកស្រាវជ្រាវបានបង្កើតជាក្រដាសតេស្ត និងមានគ្រូបន្ទុកថ្នាក់ជាអ្នកស្ដាប់នៅពេលសិស្សអានអត្ថបទផ្ទាល់មាត់ រួចធ្វើការដាក់ពិន្ទុលើពាក្យដែលសិស្សអានបានត្រឹមត្រូវនិងមិនត្រឹមត្រូវ ដើម្បីទទួលបានភាពត្រឹមត្រូវនៃការអាននិងអត្រានៃការអាន **WCPM**(ពាក្យត្រឹមត្រូវក្នុងមួយនាទី)។ ផ្អែកលើការស្រាវជ្រាវរបស់លោក**Killgallon** បានបង្ហាញថា នៅពេលសិស្សបានត្រឹមតែស្ដាប់ការអានរបស់គ្រូការបញ្ចេញសំឡេងបានត្រឹមត្រូវយ៉ាងតិច៩០%នៃពាក្យពិបាក (**គ្រូអានជាគម្រូ**) ។ ប្រសិនបើពួកគេបានធ្វើការអនុវត្តការអានជាមួយគ្រូ ការបញ្ចេញសំឡេងទៅលើពាក្យក្នុងអត្ថបទបានត្រឹមត្រូវ៩៥%នៃពាក្យពិបាក(**គ្រូនិងសិស្សអានរួមគ្នា**)។ ក្រោយពីការអនុវត្តសកម្មភាពទាំងពីរខាងលើរួចមកសិស្សអាចបញ្ចេញសំឡេងទៅលើពាក្យក្នុងអត្ថបទបានត្រឹមត្រូវ៩៨%នៃពាក្យពិបាកដោយការអានឯករាជ្យ(**សិស្សធ្វើ**) (Killgalon, 1942)។

ការសិក្សាស្រាវជ្រាវរបស់ Nina Chiulan Lin និង Hsiao-fang Cheng (2021) ផ្ដោតសំខាន់លើប្រសិទ្ធភាពនៃគោលវិធីលំនាំបង្រៀនសកម្មភាព **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** មានករណីសិក្សាមួយចំនួនដូចជា៖ យោងតាមការស្រាវជ្រាវនៅប្រទេសកាណាដា ក្នុងការបង្រៀនការអានយល់ន័យភាសាអង់គ្លេសសម្រាប់សិស្សអ៊ីរ៉ាក់ដែលមិនមែនម្ចាស់ដើម។ ការសិក្សាផ្ដោតចំពោះសិស្សថ្នាក់ទី៦មានអាយុ១១ទៅ១២ឆ្នាំនិងមានចំនួន៨០នាក់បានចូលរួម។ លទ្ធផលនៃការស្រាវជ្រាវនេះបានបង្ហាញថាអ្នកចូលរួមរហូតដល់៩៨.៧៥% តាមរយៈការធ្វើកម្រងសំណួរស្ទង់មតិរបស់សិស្ស។ តាម

លទ្ធផលនេះធ្វើឲ្យអ្នកស្រាវជ្រាវរូបនេះសន្និដ្ឋានបានថាការប្រើប្រាស់គោលវិធីបង្រៀនខាងលើពិតជាមានប្រសិទ្ធភាពក្នុងការបង្រៀនលើផ្នែកអំណាន (Yaseen, 2018)។

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាននិងអនុសាសន៍

## ៥.១.សេចក្តីសន្និដ្ឋាន

ដូចដែលបានបង្ហាញនៅផ្នែកលទ្ធផលភាពខុសគ្នារវាងក្រុមទាំងពីរក្រោយពេលបង្រៀនគឺជារឿងមួយដែលគួរយកចិត្តទុកដាក់ ព្រោះវាស្របតាមគោលបំណងនៃការស្រាវជ្រាវដែលផ្តោតលើការប្រៀបធៀបរវាងក្រុមទាំងពីរថាមួយណាមានភាពប្រសើរជាង។ យ៉ាងណាមិញ នៅក្នុងការធ្វើតេស្តសិស្សក្រុម **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** អានបានយ៉ាងល្អប្រសើរជាងមុនពេលដាក់តេស្តដើមកាល។ មួយវិញទៀត គឺក្រុមនេះមានពិន្ទុខ្ពស់ជាងក្រុម **ត្រាប់តាម** ក៏ដូចជាឈានដល់ការកំណត់ទុកជាមុនលក្ខណៈវិនិច្ឆ័យនៃ៦០ពិន្ទុ(ធៀបស្តង់ដារអំណានថ្នាក់ទី៣)ក្នុងចំណោម៧៥ពិន្ទុផងដែរ។

យោងតាមការឆ្លើយតបការស្ទង់មតិលើកម្រិតពេញចិត្តរបស់សិស្សនៃក្រុម **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** បានបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា កត្តាដែលធ្វើឱ្យសិស្សបានពិន្ទុខ្ពស់ជាងមុនពេលដាក់តេស្តដើមកាល ព្រោះសិស្សចូលចិត្តការបង្រៀនដោយប្រើប្រាស់សកម្មភាព **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** ។ សកម្មភាពបង្រៀនមួយនេះ ធ្វើឱ្យអាចចូលរួមបានច្រើនជាមួយគ្រូ មានការអនុវត្តជាមួយមិត្តភក្តិ និងបង្កើនសមត្ថភាពអំណានរបស់ខ្លួនកាន់តែប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ។

## ៥.២.ចំណុចខ្វះខាតនៃការស្រាវជ្រាវ

ចំពោះប្រធានបទមួយនេះគឺមានចំណុចគួរកែលម្អមួយចំនួន ដែលអ្នកស្រាវជ្រាវក្រោយៗពិចារណា ទី១គឺពេលវេលា ដោយក្នុងដំណើរការនៃការចុះស្រាវជ្រាវធ្វើឡើងអំឡុងពេលកម្មសិក្សាគរុកោសល្យ ដូច្នេះអ្នកស្រាវជ្រាវមានពេលតិចបំផុតក្នុងការធ្វើប្រធានបទពិសោធន៍របស់ខ្លួន។ ទី២គឺបទពិសោធ ដោយសារនេះជាលើកដំបូងរបស់អ្នកស្រាវជ្រាវ ហេតុនេះហើយតម្រូវឱ្យអ្នកសិក្សាក្រោយព្យាយាមស្វែងយល់ឱ្យកាន់តែស៊ីជម្រៅមុនពេលចុះប្រតិបត្តិការស្រាវជ្រាវរបស់ខ្លួន។ ទី៣ គឺខ្លឹមសារ ការស្រាវជ្រាវនេះមិនលម្អិតលើសកម្មភាពបង្រៀនទាំងពីរខាងលើទាំងស្រុងនោះទេគឺ

គ្រាន់តែជាការស្រាវជ្រាវដែលផ្តោតលើគោលបំណងតូចមួយរបស់អ្នកស្រាវជ្រាវដើម្បីដឹងពីភាពខុសប្លែកគ្នានៃសកម្មភាពបង្រៀនទាំងពីរប៉ុណ្ណោះ។

### ៥.៣.អនុសាសន៍

ក្នុងការស្រាវជ្រាវដោយផ្អែកលើលទ្ធផលនៃការធ្វើតេស្តអំណាននិងកម្រងសំណួរការពេញចិត្តរបស់សិស្សបានបង្ហាញថា គោលវិធីលំនាំបង្រៀនសកម្មភាព **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** អាចត្រូវបានប្រើដើម្បីជួយសម្រួលការអានរបស់សិស្សថ្នាក់ទី៣ ។ យ៉ាងណាមិញខ្ញុំបាទសូមផ្តល់អនុសាសន៍មួយចំនួនដូចតទៅ ចំពោះអ្នកស្រាវជ្រាគួរស្វែងយល់ពីបញ្ហា គោលបំណងនៃការស្រាវជ្រាវមុនចាប់ផ្តើមប្រតិបត្តិ រីឯលោកគ្រូ-អ្នកគ្រូគួរអនុវត្តន៍គោលវិធីលំនាំបង្រៀនសកម្មភាព **ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ** ឱ្យបានច្រើនក្នុងការបង្រៀនអំណានដើម្បីឱ្យសិស្សខ្លួនក្លាយជាអ្នកអានដ៏ស្ទាត់ជំនាញ។

### ៥.៤.ដែនកំណត់និងទិសដៅនាពេលអនាគតនៃការស្រាវជ្រាវ

ចំពោះការពិសោធមួយនេះផ្តោតសំខាន់លើសកម្មភាពបង្រៀននិងលទ្ធផលសិក្សារបស់សិស្ស។ ហើយមានពេលវេលាតិចតួចបំផុតសម្រាប់ការស្រាវជ្រាវគឺអំឡុងពេលចុះកម្មសិក្សាគរុកោសល្យឆ្នាំទី៤។ អនុវត្តន៍លើសិស្សចំនួនពីរថ្នាក់នៃសាលាបឋមសិក្សាពោធិវង្សខេត្តបាត់ដំបងនិងបែងចែកសិស្សជាពីរក្រុមតាមរយៈការដាក់តេស្តដើមកាល។ ទិសដៅនាពេលអនាគតគឺចង់រៀបចំតំណាងគម្រូជាពីរក្រុមដដែលនិងបន្ថែមទីតាំងចំនួនសំណាកក្នុងការស្រាវជ្រាវ។ កំណត់ពេលវេលាឱ្យមានគម្លាតច្រើនជាងនេះ ព្រមទាំងបង្កើតផែនការឱ្យបានល្អិតល្អន់។ ពិសេសជាងនេះគឺព្យាយាមរកឯកសារពាក់ព័ន្ធបន្ថែមឱ្យបានច្រើនទើបការស្រាវជ្រាវកាន់តែមានភាពជឿទុកចិត្តនិងអាចយកទៅប្រើប្រាស់បាន។

# ឯកសារយោង

Bastug, M., Keskin, H. K., & Akyol, M. (2017). How do fluent and poor reders' endurance differ in reading? *Cypriot Journal of Education Sciences, 12(4)*(4), 157-166.

Killgalon, P. A. (1942). *A study of relationships among certain puppil adjusments in reading situations.* Pennsylvania State Collage.

KiziItas, Y., & Yildiz, M. (2020, December). The study of reading fluency and reading comprehension skills ofprimary school students whose mother thongue is different. (K. E. Fa'ava, Ed.) *Waikato Journal of Education, 25*(1), 43-55.

Levy, E. (2007). *Grandual Relese of Responsiblity: I do, We do, You do.* Retrieved October 12, 2015, from http://www.sjboces.org/doc/Gifted/GrandualReleseResponsiblilityJan08.pdf

Luz, M. J. (2007). *Literature and Literacy: A Nation of Non-Readers.* Retrieved from https://old.pcij.org/stories/a-nation-of-nonreaders/

McCoy, A. (2011, March 4). *Teaching New Concepts: "I Do It, We Do It, You Do It" Method.* Retrieved October 13, 2015, from https://antoinemccoy.com/teaching-new-concepts

MoEYS. (2018). *Education in Cambodia: Findings from Cambodia's experience in PISA for Development.* Phnom Penh.

MoEYS. (2019). *សៀវភៅណែនាំគ្រូបង្រៀនថ្នាក់ទី២* (Vol. ភាគ១). ភ្នំពេញ.

MoEys. (2020). *សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី២(ភាគ២).* ភ្នំពេញ.

Panerio, R. O. (2008). *Reading Comprehension Skill of Gubat South Central School.* Unpublished Undergraduate Thesis, Biocol University Campus.

Rasinski, T. V., Padak, N. D., Mckeon, C. A., Wilfong, L. G., Friedauer, J. A., & Heim, P. (2005). Is Reading fluency a key for successful high school reading? *Jurnal of Adolescent & Adult Literacy, 49(1),* 22-27.

Shamsul, R. M. (2014). The need to incorpoate kinaesthic learning as one of primary methods in maritime English¿communication class. *ResearchGate*, 5.

Timothy, V., & Rasinski, P. (2004). *Assessing Reading Fluency.* U.S.: Pacific Resources for Education and Learning.

Tomas, M., Villaros, E., & Galman, S. (2021). The perceived challenges in Reading of Learner: Basis for School Reading Programs. *Open Journal of Social Sciences, 9,* 107-122. doi:10.4236/jss.2021.95009

Torgesen, J. K. (2000). Individual Differences in Response to Early Intervention in Reading: The Lingering Problem of Treatment Resisters. *Learning Disabilities Research and Practice, 15,* 55-64.

Yaseen, I. K. (2018). The Effect of the Using Gradual Release of Responsibility Teaching Model on Iraqi Non-EFL College Students' Achievement in Reading Comprehension. *International Journal of Management and Applied Science, ISSN: 2394-7926*.

